រាជរដ្ឋាភិបាលកម្ពុជា

សុន្ទរកថាស្វាគមន៍របស់ឯកឧត្តម ឆាយ ថន
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ
ក្នុងសិក្ខាសាលាជាតិ
ស្តីពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
គន្លឹះសំខាន់ដើម្បីគាំទ្រការអភិវឌ្ឍន៍មានសមធម៌

នៅសណ្ឋាគារកាំបូឌីយ៉ាណា, ថ្ងៃទី ៨ ខែ មករា ឆ្នាំ២០០៩
*****

សូមគោរពឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាតំណាងដ៏ខ្ពង់ខ្ពស់នៃសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

សូមគោរពគណៈអធិបតី

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ជាទីគោរព

ជាបឋម ខ្ញុំសូមអនុញ្ញាតិសំដែងនូវក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងសូមស្វាគមន៍ ព្រមទាំងសំដែងនូវការគារវភក្តីគោរពដ៏ជ្រាលជ្រៅចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់ឯកឧត្តម ផ្តល់កិត្តិយសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អង្គទូត តំណាងអង្គការជាតិ អន្តរជាតិ លោក លោកស្រី ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មមាញឹក ដើម្បីចូលរួមក្នុងសិក្ខាសាលានេះ ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ខ្ញុំសូមអនុញ្ញាតធ្វើរបាយការណ៍ដោយសង្ខេប ស្តីពីការបង្កើតកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដូចតទៅ:

ក្នុងរយៈពេលកន្លងមកនៅព្រះរាជាណាចក្រកម្ពុជា មានស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលបានប្រើប្រាស់នីតិវិធីនិងលក្ខណៈវិនិច្ឆ័យខុសៗគ្នាដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ។ ទិន្នន័យដែលស្ថាប័ន និងអង្គការទាំងនោះប្រមូលបានមានប្រយោជន៍សម្រាប់ពួកគេក្នុងការផ្តល់សេវា និងជំនួយដល់អ្នកក្រីក្រ ប៉ុន្តែលទ្ធផលទាំងនេះមិនអាចយកមកប្រៀបធៀបគ្នាបាន ហើយជាទូទៅមិនត្រូវបានចែកចាយដល់អ្នកដទៃទៀតដើម្បីប្រើប្រាស់ឡើយ ។ ដូច្នេះ ក្រសួងផែនការបានរៀបចំវេទិកាថ្នាក់ជាតិមួយ នាខែកុម្ភៈឆ្នាំ២០០៥ ដើម្បីពិភាក្សារកដំណោះស្រាយចំពោះ ស្ថានការណ៍នេះ ។ ក្នុងវេទិកានេះ មានការឯកភាពគ្នាយ៉ាងទូលំទូលាយ ស្តីពីភាពចាំបាច់ក្នុងការបង្កើតឱ្យមាននីតិវិធី ស្តង់ដារួមមួយសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលអាចកាត់បន្ថយចំណាយក្នុងការកំណត់ក្រុមគោលដៅ និងធ្វើឱ្យមានប្រសិទ្ធិភាពក្នុងការបែងចែកធនធានដ៏មានកម្រិតដល់អ្នកក្រីក្រ ។

នៅខែមេសា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានសម្រេចយល់ព្រមឱ្យបង្កើតក្រុមការងារមួយដឹកនាំដោយក្រសួងផែនការ ដើម្បីរៀបចំសេចក្តីព្រាងនីតិវិធីនិងលក្ខណៈវិនិច្ឆ័យរួម នៅថ្នាក់ជាតិសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ។ ក្រុមការងារនេះបានបង្កើតក្រុមការងារស្នូលមួយទៀត ដើម្បីទទួលខុសត្រូវលើការងារបច្ចេកទេស ដែលមានសមាជិកមកពីក្រសួងផែនការ មហាផ្ទៃ សុខាភិបាល អប់រំយុវជន និងកីឡា និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយពីអង្គការផ្សេងៗ ដូចជា អង្គការ GTZ ធនាគារពិភពលោក កម្មវិធីស្បៀងអាហារពិភពលោក UNICEF និង University Research Company (URC) ។ល។

ក្នុងឆ្នាំ២០០៥ ក្រសួងផែនការបានស្នើសុំឱ្យរដ្ឋាភិបាលអាល្លឺម៉ង់គាំទ្រទាំងថវិកានិងបច្ចេកទេស ដើម្បីបង្កើតកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងសាកល្បងអនុវត្តសេចក្តីព្រាងនីតិវិធីនេះតាមខេត្តមួយចំនួន ដើម្បីឈានទៅបង្កើតនីតិវិធីស្តង់ដារថ្នាក់ជាតិមួយដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល ។ រដ្ឋាភិបាលអាល្លឺម៉ង់បានយល់ព្រមតាមសំណើរបស់ក្រសួងផែនការ ហើយបានចុះកិច្ចសន្យាជាមួយអង្គការ GTZ ក្នុងឆ្នាំ២០០៦ ដើម្បីគាំទ្រក្រសួងផែនការទាំងថវិកានិងផ្នែកបច្ចេកទេស ។

តើអ្វីទៅជាអត្តសញ្ញាណកម្មគ្រួសារក្រីក្រ? ហើយគេធ្វើដើម្បីអ្វី ? ខ្ញុំសូមជម្រាបថា ការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាការរកឱ្យឃើញ *គ្រួសារក្រីក្រពិតប្រាកដ និងកម្រិតភាពក្រីក្រ* របស់គ្រួសារនីមួយៗដែលរស់នៅតំបន់ជនបទ ។ គោលបំណងនៃការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ គឺដើម្បីផ្តល់ទិន្នន័យអំពីគ្រួសារក្រីក្រ និងកម្រិតភាពក្រីក្រនៃឃុំ និងភូមិនីមួយៗ ដល់អ្នករៀបចំផែនការអភិវឌ្ឍន៍ និងអ្នកផ្តល់សេវានិងជំនួយ ដើម្បីកំណត់គ្រួសារនិងតំបន់គោលដៅ ។ ការផ្តល់សេវាឬជំនួយដោយផ្តោតលើគ្រួសារក្រីក្រនេះ គឺដើម្បីជួយពួកគាត់ឱ្យចាកផុតពីភាពក្រីក្រ និងការពារពួកគាត់ពីវិបត្តិផ្សេងៗ ដែលនាំឱ្យពួកគាត់កាន់តែធ្លាក់ចូលក្នុងភាពក្រីក្រ ។

ការអនុវត្តនីតិវិធីអត្តសញ្ញាណគ្រួសារក្រីក្រ ត្រូវផ្អែកលើរចនាសម្ព័ន្ធដែលមានស្រាប់ដូចជា មន្ទីរផែនការខេត្ត អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុមសម្របសម្រួលថ្នាក់ខេត្តនិងស្រុក ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការកសាង

ផែនការនិងថវិកា ហើយតាមភូមិនីមួយៗមានបង្កើតក្រុមតំណាងភូមិជាអ្នកអនុវត្តផ្ទាល់ ។ ការអនុវត្តនីតិវិធី គឺផ្អែកលើវិធីសាស្ត្របណ្តុះបណ្តាលតាមលំដាប់ ដើម្បីកសាងសមត្ថភាពអ្នកអនុវត្តនៅគ្រប់លំដាប់ថ្នាក់ ។ ការកសាងសមត្ថភាពនេះ គឺដើម្បីធានានិរន្តរភាពយូរអង្វែងនៃកម្មវិធី ។ ម្យ៉ាងទៀតមានការចូលរួមពីអ្នកភូមិក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើបញ្ជីព្រាងគ្រួសារក្រីក្រ ដើម្បីបង្កើនតម្លាភាពនៃដំណើរការអនុវត្ត ការឯកភាពរវាងអ្នកភូមិ និងសុក្រិត្យភាពនៃលទ្ធផល ។

ក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ មានចំណាត់ថ្នាក់ភាពក្រីក្រពីរគឺ ក្រកម្រិត១ (មានន័យថាក្រីក្របំផុត) និងក្រកម្រិត២ (មានន័យថាក្រីក្រ)។ ចំណាត់ថ្នាក់ភាពក្រីក្រទាំងពីរកម្រិតនេះ ត្រូវបានកំណត់ដោយផ្អែកលើសំណួរមានពិន្ទុមួយចំនួន និងសំណួរគ្មានពិន្ទុមួយចំនួនទៀតអំពីស្ថានភាពពិសេសរបស់គ្រួសារ ។

សមិទ្ធិផលសំខាន់នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតាមភូមិនីមួយៗ គឺបញ្ជីគ្រួសារក្រីក្រចុងក្រោយ ។ ម្យ៉ាងទៀត គ្រួសារក្រីក្រទាំងអស់នឹងទទួលបាននូវប័ណ្ណសមធម៌ ។ ប័ណ្ណនេះ ១) បង្ហាញឱ្យ គ្រួសារក្រីក្រដឹងថា ពួកគាត់អាចស្វែងរកសេវា ឬជំនួយផ្សេងៗដែលពួកគាត់មានសិទ្ធិនឹងទទួល ២) ជួយដល់អ្នកផ្តល់សេវាក្នុងការពិនិត្យមើលពីអត្តសញ្ញាណនៃសមាជិកគ្រួសារក្រីក្រ ដើម្បីផ្តល់សេវាដល់ពួកគាត់ ។

ខ្ញុំសូមជម្រាបថា ក្នុងឆ្នាំ២០០៧ ក្រសួងផែនការ សហការជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ បានអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះ នៅខេត្តសៀមរាប ២ស្រុកប្រតិបត្តិ (សូទ្រនិគមនិងក្រឡាញ់) និងខេត្តក្រចេះទូទាំងខេត្ត ។ ឆ្នាំ២០០៨ ក្រសួងផែនការបានពង្រីកនៅខេត្តសៀមរាប បាន២ស្រុកប្រតិបត្តិបន្ថែមទៀត (អង្គរជុំនិងសៀមរាប) ខេត្តកំពង់ចាម បាន៣ស្រុកប្រតិបត្តិ (ជើងព្រៃ-បាធាយ ចំការលើ-ស្ទឹងត្រង់ និងព្រៃឈរ-កងមាស) ខេត្តព្រៃវែង បាន២ស្រុកប្រតិបត្តិ (ពារាំងនិងព្រះស្តេច) និងខេត្តឧត្តរមានជ័យទូទាំងខេត្ត ។ សរុបទាំងអស់គ្របដណ្តប់បានចំនួន ២១០៩ ភូមិ ។

ក្នុងឆ្នាំ២០០៩ ក្រសួងផែនការនឹងពង្រីកការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទៅស្រុកប្រតិបត្តិ២បន្ថែមទៀតក្នុងខេត្តកំពង់ចាម (មេមត់និងពញ្ញាក្រែក) ស្រុកប្រតិបត្តិសំពៅមាសនៅខេត្តពោធិ៍សាត់ ស្រុកប្រតិបត្តិមង្គលបុរីនៅខេត្តបន្ទាយមានជ័យ និងគ្របដណ្តប់ទូទាំងខេត្តកំពង់ធំ កំពត និងស្វាយរៀង ។ សរុបទាំងអស់គ្របដណ្តប់បានចំនួន២៨៧៦ភូមិ ក្នុងឆ្នាំ២០០៩ ។

ក្រសួងផែនការ បានគណនាអត្រាភាពក្រីក្រជាមេដ្ឋានៃភូមិនីមួយៗ សំរាប់គ្រប់តំបន់ដែលគ្របដណ្តប់ដោយអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្នុងឆ្នាំ ២០០៧ និង២០០៨ ។ ក្នុងឆ្នាំ២០០៧ នៅតាមតំបន់គ្របដណ្តប់នៃខេត្តសៀមរាប អត្រាភាពក្រីក្រជាមេដ្ឋានគឺ ២៩.៨% ។ នៅទូទាំងខេត្តក្រចេះ អត្រាភាពក្រីក្រជាមេដ្ឋានគឺ ៣៦.៩% ។ ក្នុងឆ្នាំ ២០០៨ អត្រាភាពក្រីក្រជាមេដ្ឋាននៃភូមិក្នុងតំបន់គ្របដណ្តប់នៅសៀមរាបគឺ ២៥.៥% នៅកំពង់ចាមគឺ ៣០.៤% ហើយនៅ

ព្រៃវែងគឺ ៣៣.៧% ។ សូមបញ្ជាក់ថា នៅខេត្តទាំងនោះ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានអនុវត្ត តែនៅតំបន់មួយចំនួន ។ រីឯនៅខេត្តឧត្តរមានជ័យវិញ អត្រាភាពក្រីក្រជាមេដ្ឋានៃភូមិនីមួយៗទូទាំងខេត្ត គឺ៣០.៥% ។

ក្រៅពីតំបន់ដែលគ្របដណ្ដប់ដោយក្រសួងផែនការ ប្រតិបត្តិករមូលនិធិសមធម៌សុខភាព និងអង្គការដៃគូបានប្រើប្រាស់នីតិវិធីស្តង់ដារជាតិរបស់ក្រសួងផែនការ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅក្នុងតំបន់ផ្សេងទៀតមួយចំនួន ។ អង្គការ URC និងអង្គការ រ៉ាក់ (RHAC) បាននិងកំពុងអនុវត្តនៅខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ចាម និងក្រុងព្រះសីហនុ ។ អង្គការ URC គ្រោងអនុវត្តនៅខេត្តព្រះវិហារ រតនគិរី មណ្ឌលគីរី និងកោះកុង ក្នុងឆ្នាំ ២០០៩ ។

ដោយសារធនធាននៅមានកម្រិត ក្រសួងផែនការមានលទ្ធភាពធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងតំបន់មួយចំនួនតែប៉ុណ្ណោះ ។ ដើម្បីគ្របដណ្ដប់តំបន់ផ្សេងបន្ថែមទៀត ក្រសួងផែនការបានអនុញ្ញាតឱ្យអង្គការដៃគូមួយចំនួនកំណត់អត្តសញ្ញាណគ្រួសារក្រីក្រដោយប្រើប្រាស់នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងមានការណែនាំនិងតាមដានពីក្រសួងផែនការ ។ ដើម្បីសម្រួលការសហការគ្នា ក្រសួងបានរៀបចំ *សេចក្ដីណែនាំដល់ស្ថាប័ន និងអង្គការដៃគូ* ដែលផ្ដល់នូវការណែនាំមួយចំនួនអំពីការប្រើប្រាស់នីតិវិធីនិងលក្ខណៈវិនិច្ឆ័យរួម ដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ។

ខ្ញុំសូមជម្រាបថា ក្រសួងផែនការកំពុងរៀបចំសេចក្ដីព្រាងអនុក្រិតអំពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីបញ្ជាក់ដល់អ្នកពាក់ព័ន្ធពីគោលការណ៍ និងលក្ខខណ្ឌនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដូចជា :

- ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រដោយប្រើប្រាស់នីតិវិធីថ្នាក់ជាតិ
- ការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រដែលប្រមូលស្របតាមនីតិវិធីថ្នាក់ជាតិ សម្រាប់ផ្ដល់សេវាឬជំនួយដល់គ្រួសារក្រីក្រ
- ការបញ្ជាក់ពីរចនាសម្ព័ន្ធគ្រប់គ្រងនិងសម្របសម្រួល និងតួនាទីភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការសម្រាប់អនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ការចេញអនុក្រិតនេះ នឹងកាន់តែបញ្ជាក់ពីជំហររបស់រាជរដ្ឋាភិបាល ដែលទទួលស្គាល់និងគាំទ្រកម្មវិធី អត្ត-សញ្ញាណកម្មគ្រួសារក្រីក្រជាផ្លូវការ និងជំរុញឱ្យមានការប្រើប្រាស់ទូលំទូលាយនូវនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងទិន្នន័យអំពីគ្រួសារក្រីក្រ ដើម្បីផ្ដល់សេវា ឬ ជំនួយដល់ជនក្រីក្រ ។

ក្រសួងផែនការ គ្រោងនឹងរៀបចំធ្វើការស្រាវជ្រាវក្នុងឆ្នាំ២០០៩ ស្ដីពីសុក្រិត្យភាពនៃលទ្ធផល តម្លាភាពក្នុងការអនុវត្ត ការចូលរួមរបស់ប្រជាជន និងផលប្រយោជន៍ដែលទទួលបានធៀបនឹងការចំណាយទៅលើការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ ការស្រាវជ្រាវនេះ គឺដើម្បីរកឃើញនូវចំណុចខ្លាំងនៃកម្មវិធី និងចំណុចខ្វះខាតដែលត្រូវកែលម្អដើម្បីបង្កើនភាពជឿជាក់លើនីតិវិធី និងទិន្នន័យដែលទទួលបាន ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ក្រសួងផែនការ មានទិសដៅអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងតំបន់ជនបទទូទាំងប្រទេសកម្ពុជាក្នុងអនាគតដ៏ខ្លី និងធ្វើបច្ចុប្បន្នភាពបញ្ជីគ្រួសារក្រីក្រ២ឆ្នាំម្តង ។ ក្នុងពេលឆាប់ៗនេះ ក្រសួងនឹងរៀបចំផែនការមេដើម្បីឈានទៅកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រអោយបានពាក់កណ្តាលប្រទេសក្នុងឆ្នាំ ២០១០ និងបន្តទៅពាក់កណ្តាលទៀតនៅឆ្នាំ ២០១១ ។ ដើម្បីសម្រេចឱ្យបាននូវផែនការនេះ ក្រសួងផែនការ នឹងត្រូវការធនធានគ្រប់គ្រាន់និងជាប្រចាំពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ ក្នុងដំណាក់កាលនេះ ជាការចាំបាច់ណាស់រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គួរបង្កើត**កញ្ចប់ថវិការួម** (Trust Fund) ដែលក្នុងក្របខ័ណ្ឌកញ្ចប់ថវិកានេះ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានានឹងមានលទ្ធភាពរួមចំណែកផ្តល់ថវិកាសម្រាប់គាំទ្រកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ កញ្ចប់ថវិកានេះនឹងពង្រឹងនិរន្តរភាពនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីផ្តល់ទិន្នន័យដ៏មានសារៈប្រយោជន៍ ដល់ស្ថាប័ននិងអង្គការ សំរាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកំណត់ក្រុមគោលដៅដើម្បីផ្តល់សេវាឬជំនួយ ។ ធនាគារពិភពលោកនិងក្រសួងផែនការកំពុងសហការគ្នាដើម្បីបង្កើតកញ្ចប់ថវិការួមមួយក្នុងឆ្នាំ ២០០៩ សំរាប់គាំទ្រផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ ដែលក្នុងនោះមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាសកម្មភាព គោលដៅមួយផងដែរ ។

មុននឹងបញ្ចប់ ក្នុងនាមក្រសួងផែនការ ជាថ្មីម្តងទៀត ខ្ញុំសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់ចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានអញ្ជើញចូលរួមជាអធិបតីក្នុងសិក្ខាសាលាជាតិ ស្តីពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងថ្ងៃនេះ ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោកតំណាងអង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងលោក លោកស្រីទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងសិក្ខាសាលានេះ ។ ជាពិសេសសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះមន្ត្រីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់ក្រសួងមហាផ្ទៃ ដែលបានសហការល្អជាមួយក្រសួងផែនការ ជំរុញការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រឱ្យទទួលបានជោគជ័យ ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលសហព័ន្ធអាល្លឺម៉ង់ ដែលបាននិងកំពុងផ្តល់ការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងចំពោះរដ្ឋាភិបាលអូស្ត្រាលី ដែលគ្រោងនឹងផ្តល់ថវិកាគាំទ្រកម្មវិធីនេះ ក្នុងពេលឆាប់ៗខាងមុខ ។

ខ្ញុំសូមគោរពជូនពរ ចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី បានប្រកបដោយសេចក្តីសុខចំរើន និងទទួលបានជោគជ័យដ៏ត្រចះត្រចង់ថ្មីៗថែមទៀតកុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ